**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ**
**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ**
លេខៈ...០៦៩.....សហអ

**<u>សូមគោរពជូន</u>**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

<u>តាមរយៈ</u> ឯកឧត្តមអគ្គនាយកពាណិជ្ជកម្មអន្តរជាតិ
<u>កម្មវត្ថុៈ</u> របាយការណ៍ស្តីពីកិច្ចប្រជុំគណៈកម្មការអនុវត្តន៍ (IC) លើកទី១៧
<u>ភ្ជាប់ជូនៈ</u> របៀបវារៈនៃកិច្ចប្រជុំ និងបញ្ជីវត្តមាន

ឆ្នាំពីរពាន់ដប់ពីរ ខែមីនា ថ្ងៃទី ប្រាំពីរ នៅក្រសួងពាណិជ្ជកម្មបានបើកកិច្ចប្រជុំនៃគណៈកម្មការអនុវត្តន៍ (IC) លើកទី១៧ ក្រោមអធិបតីភាព **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការអនុវត្តន៍(IC)ដោយមានសមាជិក សមាជិកា នៃគណៈកម្មាការមកពីក្រសួងស្ថាប័នដែលពាក់ព័ន្ធចូលរួមពិភាក្សាលើរបៀបវារៈដូចដែលបានគ្រោងទុក ។

របៀបវារៈកិច្ចប្រជុំ និងចំណុចសំខាន់ៗដែលបានពិភាក្សារួមមានៈ

- របាយការណ៍វឌ្ឍនភាពរបស់គម្រោង TDSP & EIF

បន្ទាប់ពីលោក **ឈៀង ពេជ្រ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិបានរាយការណ៍ជូនកិច្ចប្រជុំអំពីវឌ្ឍនភាពរបស់គម្រោង TDSP រួមមានៈ (ការបន្តគម្រោង TDSP , ការដាក់កំណត់ថ្មីដោយធនាគារពិភពលោកសម្រាប់ឆ្នាំ២០១២, ការងារថវិកា, ការងារលទ្ធកម្ម, ការអនុវត្តន៍គម្រោង) និង របាយការណ៍វឌ្ឍនភាពរបស់គម្រោង EIF ដែលក្នុងនោះមានការងារថវិកា, ការអនុវត្តន៍, និង Mid Term Review (សូមមើលនៅក្នុង Presentation Slide ) ព្រមទាំងការបង្ហាញជូននូវគំរូរបាយការណ៍វាយតម្លៃអំពីការអនុវត្តន៍ការងាររបស់ទីប្រឹក្សា (Consultant Performance Evaluation Report) ដោយលោក **សួស សុមេត** ទីប្រឹក្សា Project Implementation Advisor (សូមមើលនៅក្នុងឧបសម្ព័ន្ធ I ) រួចមក ជូសមុខគណៈកម្មាការអនុវត្តន៍គម្រោង (IC) **ឯកឧត្តម ប៉ាន សូរស័ក្តិ** បានធ្វើការបូកសរុបជាលទ្ធផលរួម និងផ្តល់អនុសាសន៍ដូចខាងក្រោមៈ

- ទទួលស្គាល់របាយការណ៍វឌ្ឍនភាពរបស់គម្រោង TDSP និង EIF ។
- ឯកភាពលើគំរូរបាយការណ៍ Consultant Performance Evaluation Report និងឲ្យដាក់ក្នុង Website ដើម្បី ឲ្យភ្នាក់ងារអនុវត្តន៍គម្រោង (IAs) អាច download បាន ។
- ឯកភាពលើការលើកគម្រោង Fishery Project ទៅតំណាក់កាលទី២ (Phase II) ។
- សុំឲ្យ IAs ផ្ញើលិខិតសុំបន្តការអនុវត្តន៍គម្រោងរបស់ខ្លួនមក DICO ឲ្យបានឆាប់បំផុត ។
- ឯកភាពការបន្តកិច្ចសន្យារបស់លោក Sven Callebaut ទីប្រឹក្សាអន្តរជាតិនៅក្នុងគម្រោង EIF ។

- ជូន **ឯកឧត្តម** អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ ពិនិត្យលទ្ធភាពចំពោះការផ្លាស់ប្តូរសមាជិក សមាជិកា របស់គណៈកម្មការអនុវត្តន៍ IC, Trade SWAp, និងគណៈកម្មការលទ្ធកម្ម ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ០៩:០០ ក្នុងបរិយាកាសរីករាយ និងប្រកបដោយលទ្ធផលល្អ ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តម** មេត្តាជ្រាបជារបាយការណ៍ និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី៩ ខែ មីនា ឆ្នាំ២០១២

អ្នកធ្វើរបាយការណ៍

សេង វ៉ាមី

បានឃើញ និង ឯកភាព

16 03 2012

ម៉ម ម៉ានី

អនុប្រធាននាយកដ្ឋាន

គោរពជូន **ឯកឧត្តមរដ្ឋលេខាធិការ**

ដើម្បីសុំការឯកភាពគោរពបញ្ជូនជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** ជ្រាប

21/03/2012

**សុខ សុភ័ក្រ្ត**

សមាជិកអចិន្ត្រៃយ៍ គណៈកម្មាការអនុវត្តគម្រោង

បានឃើញ និង ឯកភាព

គោរពបញ្ជូនជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី**

**ប៉ាន សូរស័ក្តិ**

ប្រធានគណៈកម្មាការអនុវត្តគម្រោង

__ចម្លងជូនៈ__

- ឯ.ឧ ប្រធាន - អនុប្រធាន និងសមាជិកគណៈកម្មការអនុវត្តគម្រោង
- ឯ.ឧ លោក - លោកស្រី ប្រធានក្រុមការងារសរស្តម្ភទី១ ទី២ និងទី៣